# លិខិតបើកចំហ

## សូមគោរពជូន ៖

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រថៃឡង់**
**នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម**
**នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

**កម្មវត្ថុ៖** ស្នើសុំបញ្ឈប់គំរោងសាងសង់ទំនប់វារីអគ្គិសនី **ដន សាហុង** និងផ្អាកការសម្រេចចិត្តលើគំរោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅលើតួទន្លេមេនៃទន្លេមេគង្គ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ នាយករដ្ឋមន្ត្រីនៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ មេត្តាជ្រាបថា ទំនប់វារីអគ្គិសនី **ដន សាហុង** ដែលមានថាមពល២៦០មេហ្គាវ៉ាត់ គឺជាទំនប់មួយក្នុងចំណោមគម្រោងទំនប់វារីអគ្គិសនីទាំង១១ដែលគ្រោងសាងសង់នៅលើតួទន្លេមេនៃទន្លេមេគង្គក្រោម។ បច្ចុប្បន្ន គំរោងនេះកំពុងត្រូវបានចាប់ផ្តើមសិក្សា និងដាក់សំណើសម្រាប់ការសាងសង់បន្ទាប់ពីទំនប់វារីអគ្គិសនីសាយ៉ាបូរី។ គំរោងនេះមានទីតាំងស្ថិតនៅចំងាយ២គីឡូម៉ែត្រ ពីព្រំដែនកម្ពុជា-ឡាវ ក្នុងខេត្ត ចំប៉ាសាក់ ប្រទេសឡាវ។ អគ្គិសនីបានពីទំនប់ **ដន សាហុង** ត្រូវបានគ្រោងទុកសំរាប់នាំចេញទៅកាន់ប្រទេសថៃ។ ប្រសិនបើទំនប់ត្រូវបានសាងសង់វានឹងរាំងខ្ទប់ច្រកហ៊ូសាហុង ដែលជាដៃទន្លេដ៏ធំមួយដែលរួមនឹងផ្នែកល្បាក់ខោននៃទន្លេមេគង្គ។ ទំនប់នេះទទួលការវិនិយោគដោយក្រុមហ៊ុន ម៉េហ្គាហ្វឺស (Mega First Corporation Berhad, MFCB) នៃប្រទេសម៉ាឡេស៊ី។

ក្នុងខែតុលា ឆ្នាំ២០១៣ រដ្ឋាភិបាលឡាវបានជូនដំណឹងទៅគណៈកម្មាការទន្លេមេគង្គ (MRC) ថាទំនប់ដនសាហុង «គឺមិនស្ថិតនៅលើតួទន្លេមេនៃទន្លេមេគង្គទេ» ដែលគ្រាន់តែតម្រូវឲ្យមាន *«ការជូនដំណឹងជាមុន»* ជំនួសការ *«ការពិគ្រោះយោបល់មុន»*។ ផ្ទុយទៅវិញលេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ (MRC) បានបង្ហាញថា «ដនសាហុងគឺជាទំនប់ស្ថិតនៅលើតួទន្លេមេនៃទន្លេមេគង្គ» ដែលមានទាំងក្នុងផែនការអភិវឌ្ឍន៍អាង (BDP) និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្រ្ត(SEA) នៃទំនប់ស្ថិតនៅលើតួទន្លេមេនៃទន្លេមេគង្គផង។ ឯកសារទាំងអស់នេះក៏ត្រូវបានយល់ព្រមដោយរដ្ឋាភិបាលឡាវផងដែរ។ ប៉ុន្តែ រហូតមកដល់បច្ចុប្បន្ននេះមិនទាន់មានការបង្ហាញអំពីឆន្ទៈរបស់ប្រទេសឡាវក្នុងការពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងប្រជាពលរដ្ឋដែលរស់តាមដងទន្លេមេគង្គនៅកម្ពុជាឡើយ។ បើយោងតាមរយៈការចុះទៅដល់ទីតាំងនៃគំរោងអភិវឌ្ឍន៍ទំនប់ ដន សាហុង និងការចូលរួមប្រជុំជាមួយតំណាងគណៈកម្មការទន្លេមេគង្គ ដៃគូអភិវឌ្ឍន៍ និង អ្នកស្រាវជ្រាវពាក់ព័ន្ធនឹងទំនប់នេះ ក្នុងកំឡុង ថ្ងៃទី ១១-១២ ខែ មីនា ឆ្នាំ ២០១៤ កន្លងទៅនេះ យើងខ្ញុំជាតំណាងសង្គមស៊ីវិលបានសង្កេតឃើញថា ៖

១. មិនមានការសិក្សាស្រាវជ្រាវឲ្យបានស៊ីជំរៅអំពីធនធានជលផល ការធ្វើចរាចរណ៍ត្រីពីផ្នែកខាងក្រោមទៅផ្នែកខាងលើនៃតំបន់ស៊ីផាន់ដន ធនធានជលផលនៅតំបន់វ៉ាមសារ ខេត្តស្ទឹងត្រែង និងជម្រើសសំរាប់ការធ្វើចរាចរណ៍ត្រី ធនធានជលផល និងសត្វផ្សោតទន្លេមេគង្គ។

២. មិនទាន់បានអនុវត្តន៍ ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) និងការវាយតំលៃហេតុប៉ះពាល់បរិស្ថានជាយុទ្ធសាស្ត្រ ជាមួយប្រទេសផ្នែកខាងក្រោម

៣. មិនមានការវាយតម្លៃហេតុប៉ះពាល់ឆ្លងដែននៅក្នុងប្រទេសកម្ពុជា ក៏ដូចជាដីសណ្តរទន្លេមេគង្គ

លើសពីនេះទៀត បើយោងតាមការសិក្សាថ្មីៗរបស់វិទ្យាស្ថានស្រាវជ្រាវជលផលទឹកសាប (IFReDI) បានគូសបញ្ជាក់ពីការផ្លាស់ប្តូរយ៉ាងខ្លាំងក្នុងការនេសាទត្រីទឹកសាប ដោយសារតែការអភិវឌ្ឍទំនប់វារីអគ្គិសនីលើតួទន្លេមេនៃទន្លេមេគង្គដែលអាចមានផលប៉ះពាល់អវិជ្ជមានលើសន្តិសុខស្បៀង អាហាររូបត្ថម្ភ និងសុខភាពសាធារណៈ។ របកគំហើញនៃការស្រាវជ្រាវមួយទៀតស្តីពី «ទន្លេសាបនាពេលបច្ចុប្បន្ន និងអនាគត» បានបង្ហាញថាការអភិវឌ្ឍទំនប់វារីអគ្គិសនីលើតួទន្លេមេនៃទន្លេមេគង្គគឺរំពឹងថានឹងផ្តល់ផលប៉ះពាល់ជាចំបងលើ បរិស្ថាន សង្គម និងសេដ្ឋកិច្ចនៃប្រព័ន្ធបឹងទន្លេសាប។

អាស្រ័យដូចនេះយើងខ្ញុំរួមមាន សម្ព័ន្ធទន្លេកម្ពុជា (RCC) និង តំណាងសហគមន៍ទន្លេមេគង្គ និងទន្លេសាប (រួមមានស្នាមមេដៃភ្ជាប់មកជាមួយ) មានកិត្តិយសសូមគោរពជម្រាបជូន សម្តេច ឯកឧត្តម លោកជំទាវ នាយករដ្ឋមន្ត្រី នៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ មេត្តាជ្រាបបន្ថែមទៀតថា ប្រជាពលរដ្ឋ ក៏ដូចជាសង្គមស៊ីវិល និងអង្គការជាដៃគូ មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះគម្រោងសាងសង់ទំនប់វារីអគ្គិសនីនៅលើតួទន្លេមេនៃទន្លេមេគង្គ ជាពិសេសគឺ ទំនប់ ដន សាហុង ហើយបានមូលមតិគ្នារៀបចំវេទិកា សិក្ខាសាលា យុទ្ធនាការ ការផ្សព្វផ្សាយតាមប្រព័ន្ធសារព័ត៌មានយ៉ាងច្រើន រួមទាំងថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់អាស៊ាន និងថ្នាក់អន្តរជាតិ ដើម្បីលើកឡើងពីកង្វល់របស់ខ្លួនឲ្យបានឮ ទៅដល់ស្ថាប័នពាក់ព័ន្ធ រួមទាំង ថ្នាក់ដឹកនាំអាស៊ានក្នុងពេលថ្មីៗកន្លងមកនេះ ដើម្បីទទូចដល់ថ្នាក់ដឹកនាំកំពូលធ្វើការពិចារណាឡើងវិញចំពោះគម្រោងទំនប់វារីអគ្គិសនីនៅលើតួទន្លេមេនៃទន្លេមេគង្គ ដោយស្នើរដ្ឋាភិបាលឡាវធ្វើការពិចារណាបញ្ឈប់គំរោងសាងសង់ទំនប់វារីអគ្គិសនីដន សាហុង និងផ្អាកការសម្រេចចិត្តលើគំរោងគំរោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីនៅលើតួទន្លេមេនៃទន្លេមេគង្គ ។

សូម សម្តេច ឯកឧត្តម លោកជំទាវ នាយករដ្ឋមន្ត្រី នៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៤

**តំណាង « សម្ព័ន្ធទន្លេកម្ពុជា » និង សហគមន៍ទន្លេមេគង្គ និង ទន្លេសាប ៖**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

បណ្តាញការពារទន្លេសេសាន ស្រែពក សេកុង

សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌
អង្គការស្ម័គ្រចិត្តដើម្បីសង្គម
អង្គការថែរក្សាជនជាតិដើមភាគតិចកម្ពុជា
អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍
អង្គការអាដហុក
សមាគមន៍កសិករខ្មែរ
អង្គការអភិវឌ្ឍន៍ជនបទភូមិភាគឦសាន
អង្គការមាតាធម្មជាតិ
អង្គការពន្លកខ្មែរ
អង្គការម្លប់ព្រហ្មវិហារធម៌
អង្គការសហប្រតិបត្តិការបរិស្ថាន និង ទេសចរណ៍
ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា
អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា
អេកូសានថាមពលកម្ពុជា
តំណាងសហគមន៍បឹងទន្លេសាប
តំណាងសហគមន៍ទន្លេមេគង្គ

**ចម្លងជូនៈ**
ក្រសួងធនធានទឹក និង ឧតុនិយម
គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
គណៈកម្មាធិការជាតិទន្លេមេគង្គឡាវ
គណៈកម្មាធិការជាតិទន្លេមេគង្គវៀតណាម
គណៈកម្មាធិការជាតិទន្លេមេគង្គថៃ
គណៈកម្មការទន្លេមេគង្គ
ក្រសួងរ៉ែ និង ថាមពល
ក្រសួងបរិស្ថាន
ក្រសួងទេសចរណ៍
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
ក្រសួងកិច្ចការនារី
ដៃគូអភិវឌ្ឍន៍
អ្នកសារព័ត៌មានជាតិ និង អន្តរជាតិ

*ផ្ទះលេខ ៩-១១ ផ្លូវ ៤៧៦ ទួលទំពូង១ ភ្នំពេញ ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ-៣* *# 9-11, St476, Toul Tompoung1,Phnom Penh, P.O. Box 2295 Phnom Penh-3 Tel: (855) 23 214 429 Fax: (855) 23 994 063*